ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ២៥៩
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨
សាលដីកា
លេខៈ៣១ "V"
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោកស្រី [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២២៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] MICHAEL P ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៥២ ក្រII"ប" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ៖**

-ឈ្មោះ [redacted] MICHAEL P ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិអាមេរិកកាំង មុខរបរគ្រូបង្រៀន ទីកន្លែងកំណើតនៅរដ្ឋCalifornia ប្រទេសសហរដ្ឋអាមេរិក ទីលំនៅមុនពេលឃុំខ្លួននៅ [redacted]

Scanned with CamScanner

[redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន។ (ក្នុងឃុំ) (អ្នកប្ដឹងសាទុក្ខ)

-មានមេធាវីការពារសិទ្ធិលោកស្រី [redacted] យក់ហៀប

-មានអ្នកបកប្រែភាសាលោក [redacted] វណ្ណា

-ជាប់ចោទពីបទៈ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម១៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុៈ**

កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង១៣ និង៣០នាទី ស្ថិតនៅក្រុម១៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀន សហការជាមួយកម្លាំងការិយាល័យចរាចរណ៍ បានបង្ក្រាបករណីជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមួយករណី ឃាត់ខ្លួនបានឈ្មោះ [redacted] MICHAEL P ភេទប្រុស អាយុ៦៩ឆ្នាំ ជនជាតិអាមេរិកកាំង រួមជាមួយនឹងវត្ថុតាងជាសារធាតុញៀន ដូចជាថ្នាំញៀនប្រភេទ មេតំហ្វេតាមីនទឹកកក ចំនួន០១កញ្ចប់ មានទម្ងន់៣,៨៧ក្រាម(ទម្ងន់សុទ្ធ) កញ្ចារក្រៀមចំនួន០១ថង់តូច ទម្ងន់៨,៤១ក្រាម និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១គ្រឿង ព្រមទាំងសេរាំងសម្រាប់ចាក់ចំនួន០២។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៧ “ជ” ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោស ឈ្មោះ [redacted] MICHAEL P ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិអាមេរិកកាំង (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី) ឆ្នាំ និង០៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន ៤,000,000៛(បួនលានរៀល) ចូលថវិការរដ្ឋ។

ពីបទៈ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម១៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

២-វត្ថុដែលចាប់យកៈ

Scanned with CamScanner

ក.ប្រគល់ឱ្យម្ចាស់ដើមវិញនូវ៖ លិខិតឆ្លងដែនចំនួន០៣(បី) ក្បាល និងម៉ូតូចំនួន០១គ្រឿង ម៉ាកអែប្លែដ ពណ៌ក្រហម។

ខ.រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ៖ ទូរស័ព្ទដៃចំនួន០១គ្រឿង តាមបញ្ញត្តិមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

គ.រឹបអូស សេរ៉ាំងចំនួន០២ដើម, ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនចំនួន០១គ្រឿង រុក្ខជាតិក្រៀមជាកញ្ឆា ចំនួន០១កញ្ចប់ ទម្ងន់៨,៤១ ក្រាម និងថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន០១(មួយ) កញ្ចប់ទម្ងន់៣,៨៧ក្រាម តាមបញ្ញត្តិមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

៣-បណ្តេញជនជាប់ចោទចេញពីប្រទេសកម្ពុជា នៅពេលអនុវត្តទោសដាក់ពន្ធនាគារចប់។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ១០៣ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] MICHAEL P ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ "ជ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន០៣ឆ្នាំ ០៦ខែ នៃសេចក្តីសម្រេចបញ្ចប់ក្នុងសាលក្រម។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៥២ ក្រII"ប" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ១០៣ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] MICHAEL P ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣៧ "ជ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការទាំងមូល។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ២២៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] MICHAEL P ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៥២ ក្រII "ប" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។



Scanned with CamScanner

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា៖ សាលាដំបូងខេត្តព្រះសីហនុបានសម្អាងហេតុថា ជនជាប់ចោទត្រូវបានសមត្ថកិច្ចចាប់បាន និងឆែកឆេរឃើញថា មានជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន និងគ្រឿងញៀនជាក់ស្តែងនៅនិងជនជាប់ចោទ ដែលផ្ទុយពីការប្រកែកថា ខ្លួនមកប្រើប្រាស់ជាមួយស្រីស្អាតៗនោះទេ។

យល់ឃើញថា: ភស្តុតាង និងសកម្មភាពរួមទាំងវត្ថុតាងពិតជាបង្ហាញឱ្យឃើញថា ជាអំពើល្មើសនិងមាត្រា៤០ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

១-ទទួល បណ្តឹងសាទុក្ខលេខ ២២៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] MICHAEL P ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៥២ “ក្រII.ប” ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

ជនជាប់ចោទឈ្មោះ [redacted] MICHAEL P បានឆ្លើយថា ខ្ញុំបាទកើតទុក្ខមិនសុខចិត្ត និងភស្តុតាងទាំងអស់នៅតុលាការថ្នាក់ក្រោម ទើបខ្ញុំប្តឹងសាទុក្ខមកតុលាការកំពូល ដោយសារគ្រឿងញៀននោះ មិនមែនជារបស់ខ្ញុំទេ នៅក្នុងសាលក្រមសាលាដំបូង ចំណុចខ្លះខ្ញុំពិបាកទទួលយកណាស់ និងនៅដំណាក់កាលចៅក្រមស៊ើបអង្កេតគ្មានអ្នកបកប្រែភាសាអោយខ្ញុំទេ ហើយខ្ញុំក៏បានចុះហត្ថលេខាទទួលស្គាល់ទាំងមិនបានដឹងថាគេ សរសេរចោទប្រកាន់ខ្ញុំពីរឿងគ្រឿងញៀន និងរួមរ័កជាមួយស្ត្រីទេ។ នៅថ្ងៃកើតហេតុមានស្ត្រីម្នាក់មកគោះទ្វារបន្ទប់ខ្ញុំ និងសុំអង្វរឱ្យខ្ញុំជួយ ព្រោះមានមនុស្សប្រុសជនជាតិបារាំងម្នាក់រករឿងគាត់ ស្ត្រីនោះមានកាបូបមួយដែលមានគ្រឿងញៀននៅក្នុងនោះ និងបានសុំអោយខ្ញុំជួយលាក់កាបូបនោះទៀតផង ខ្ញុំក៏បានយល់ព្រមជួយលាក់កាបូបដែលមានផ្ទុកគ្រឿងញៀនរបស់ស្ត្រីនោះពិតប្រាកដមែន។ នៅថ្ងៃចាប់ខ្លួនប៉ូលីសបានឆែកឆេរឃើញកាបូបដែលមានគ្រឿងញៀនរបស់ស្ត្រីនោះដែលអោយខ្ញុំជួយលាក់ ក្នុងសាកកាដូស្ពាយរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបានប្រើប្រាស់ថ្នាំញៀនទេ។

សំណូមពរ ខ្ញុំព្រមទទួលស្គាល់កំហុសពីរឿងលាក់គ្រឿងញៀន ប៉ុន្តែចំពោះរឿងដែលចោទប្រកាន់ខ្ញុំពីរឿងរួមរ័កជាមួយស្ត្រីនោះ គឺមិនមានទេ និងសុំអោយពេលខ្ញុំអនុវត្តទោសចប់ សូមកុំបណ្តេញខ្ញុំចេញពីប្រទេសកម្ពុជាអី ខ្ញុំនិងចាកចេញដោយខ្លួនឯង។

Scanned with CamScanner

លោកស្រី [redacted] យក់ហៀប មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា សូមក្រុមប្រឹក្សាមេត្តាពិចារណា ទាក់ទងទៅនិងមូលហេតុដែលគាត់បានទទួលកាបូប-របស់ស្ត្រីនោះ គឺគាត់មិនបានសួរនាំជាមុនទេ ស្ត្រីនោះបានទុកកាបូបក្នុងបន្ទប់ ហើយលួចចេញទៅមុនបាត់ កូនក្តីខ្ញុំមិនបានដឹងមុនទេថាជាគ្រឿងញៀន ប្រសិនបើដឹងម្ល៉េះគាត់យកទៅលាក់ ឬយកទៅបង្ហាញសមត្ថកិច្ចថានេះជាគ្រឿងញៀន ថាជារបស់ស្ត្រីនោះបាត់ទៅហើយ ប៉ុន្តែដោយចៃដន្យពេលគាត់កំពុងបើកបរ គាត់ជិះម៉ូតូខុស ប៉ូលីសចរាចរណ៍បានហៅគាត់ឱ្យឈប់ និងឆែកឆេរគាត់ ក៏បានឃើញគ្រឿងញៀនក្នុងកាបូបនោះ គាត់ទើបតែដឹងពេលប៉ូលីសឆែកឃើញនេះ មិនមែនគាត់ដឹងមុនទេ។ គាត់ទទួលស្គាល់ពីរឿងរក្សាទុកគ្រឿងញៀន ប៉ុន្តែគាត់សុំបដិសេធរឿងដែលចោទប្រកាន់គាត់ពីការប្រើប្រាស់ ថ្ងៃចាប់ខ្លួនគាត់បានសុំអោយប៉ូលីសពិនិត្យខ្លួនគាត់ដែរ តែប៉ូលីសមិនបានពិនិត្យទេ ហើយការជួញដូរគ្រឿងញៀនក៏គាត់គ្មានដែរ។ សុំក្រុមប្រឹក្សាពិចារណាលើ មាត្រា៩៣,៩៤ និងមាត្រា១០៧,១០៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

សំណូមពរ ដោយសារគាត់បានជាប់ពន្ធនាគារ០៣ឆ្នាំហើយ សុំឱ្យតុលាការបន្ធូរបន្ថយទោសដែលនៅសល់០៦ខែទៀតនេះជូនគាត់ផង។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] មៃឃើល ភី [redacted] MICHAEL P) ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទជាបុគ្គលប្តឹងសាទុក្ខឈ្មោះ [redacted] មៃឃើល ភី [redacted] MICHAEL P) ត្រូវបានតុលាការអង្គហេតុប្រកាសទោសដាក់ពន្ធនាគារចំនួន៣ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ចំនួន៤,000,000 (បួនលាន)រៀល ពីបទៈជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២។ ករណីនេះពិនិត្យឃើញថា ការដែលសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ផងដែរ ដែលបានកំណត់ពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] មៃឃើល ភី ( [redacted] MICHAEL P) ក្នុងបទល្មើសត្រួតពាក់ព័ន្ធនឹង



Scanned with CamScanner

អំពើជួញដូរគ្រឿងញៀនដោយខុសច្បាប់ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ នោះ មិនមានលក្ខណៈត្រឹមត្រូវទេ ព្រោះថាតាមមាត្រា៤០ (បទៈរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន) កថាខណ្ឌ៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា "ការផ្តល់សម្រាប់លក់ ការទិញដើម្បីលក់ ឬដោះដូរ ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"។ ឯពិនិត្យភស្តុតាងដាក់បន្ទុកនានា ដូចជាចម្លើយសារភាពរបស់ជនជាប់ចោទនៅចំពោះមុខមន្ត្រី នគរបាលយុត្តិធម៌ ក៏ដូចជាចំពោះមុខអាជ្ញាធរតុលាការសាលាដំបូង បង្ហាញថាជនជាប់ចោទបានទិញ គ្រឿងញៀនដោយខុសច្បាប់ ដើម្បីរក្សាទុក និងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្តល់ជូនទៅតតិយជន ដោយឥតយកកម្រៃ ហើយក៏គ្មានភស្តុតាងដាក់បន្ទុកច្បាស់លាស់ថាជនជាប់ចោទរូបនេះ ធ្វើសកម្មភាពស្របតាមការកំណត់ន័យក្នុងអំពើជួញដូរគ្រឿងញៀនទេ។ ដូច្នេះ កម្រិតភស្តុតាងដាក់បន្ទុកក្នុងអំពើជួញដូរគ្រឿងញៀនស្ថិតក្នុងវិមតិសង្ស័យជាខ្លាំង ដែលគប្បីតុលាការកំពូលពិចារណា និងសម្រេចតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៣៥១(អវត្តមានរបស់ជនជាប់ចោទ) កថាខណ្ឌ១, ៤៤០(ការបដិសេធដោយគ្មានបង្វិលសំណុំរឿង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ម៉្យាងវិញទៀត ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុលាការអង្គហេតុ ដែលសម្រេចបណ្តេញជនជាប់ចោទចេញពីប្រទេសកម្ពុជា នៅពេលអនុវត្តទោសពន្ធនាគារចប់នោះឃើញថា គ្មានសំអាងហេតុ និងមិនមានលក្ខណៈស្របនឹងមាត្រា៣៤ (ទោសបន្ថែមសម្រាប់រូបវន្តបុគ្គល) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ទេ។ ដូច្នេះ តាមស្មារតីមាត្រា៤១៩, មាត្រា៤៣៦, មាត្រា៤០៤ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងផលប្រយោជន៍ច្បាប់ គប្បីតុលាការសម្រេចលុបចោលសេចក្តីសម្រេចត្រង់ចំណុចទី៣ៈស្តីពីការបណ្តេញចេញជនជាប់ចោទ នៃសាលក្រមលេខ៣៧"ជ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ។

៣-យល់ឃើញថា ការដែលជនជាប់ចោទបានធ្វើការកត់សម្គាល់ ក៏ដូចជាលោកស្រីមេធាវីការពារក្តី បានធ្វើសេចក្តីសន្និដ្ឋានថា ភាគីខ្លួនទទួលស្គាល់អំពីកំហុសពាក់ព័ន្ធនឹងគ្រឿងញៀន ដែលមានក្នុងកាបូបរបស់ខ្លួន ហើយភាគីខ្លួនជាជនជាប់ចោទបានស្ថិតក្នុងការឃុំខ្លួន មានថេរវេលាឃុំខ្លួនជិតស្មើនិងរយៈពេលនៃទោសដែលតុលាការអង្គហេតុបានប្រកាស ហេតុនេះស្នើសុំឱ្យតុលាការកំពូលពិចារណាសម្រេចបន្ថែមតាមមាត្រា៩៣ និង៩៤ នៃក្រមព្រហ្មទណ្ឌទៀតនោះជាការមិនត្រឹមត្រូវទេ ព្រោះថាការពិចារណា និងសម្រេចអំពីស្ថានសម្រាលទោស គឺជាសមត្ថកិច្ចរបស់តុលាការអង្គហេតុ ដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការកំពូលនាពេលនេះ ដែលពិចារណាតែលើអង្គច្បាប់ផ្អែកតាមបញ្ញត្តិមាត្រា៤១៩, មាត្រា៤៣៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

៤-យល់ឃើញថា តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា រឿងក្តីនេះ ជាប្រភេទបទល្មើសជាក់ស្តែង និងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អស់ហើយ ហេតុនេះ សុំឱ្យតុលាការកំពូលពិចារណាទៅ



Scanned with CamScanner

តាមទិដ្ឋភាពច្បាប់ដោយតម្កល់សាលដីការបស់សាលាឧទ្ធរណ៍។ ចំណុចនេះតុលាការកំពូល បានពិចារណាដូចមានក្នុងសំអាងហេតុខាងលើនេះ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥២ ក្រ II "ប" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ លើកលែងតែបទល្មើសជួញដូរគ្រឿងញៀន និងសេចក្តីសម្រេចត្រង់ចំណុចស្តីពី ការបណ្តេញចេញជនជាប់ចោទ ដែលត្រូវសម្រេចជាថ្មី។

## ហេតុដូច្នេះ

## សម្រេច

១.បដិសេធ ផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ២២៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] មៃឃើល ភី ( [redacted] MICHAEL P)។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៥២ ក្រ II "ប" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែឈ្មោះបទល្មើសជួញដូរគ្រឿងញៀន និងសេចក្តីសម្រេចត្រង់ចំណុចទី៣ៈ ស្តីពីការបណ្តេញចេញជនជាប់ចោទ នៃសាលក្រមលេខ៣៧ "ជ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលត្រូវបដិសេធចោល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner